01148399

E341/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
23 / 09 / 2015
ម៉ោង (Time/Heure) : 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៥

ជូនចំពោះ៖ គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២

ពី៖ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន៖ លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

កម្មវត្ថុ៖ បែបបទថ្មីស្តីពីការប្រើប្រាស់ប្រព័ន្ធដាក់ឯកសារសម្រាប់សវនាការប្រចាំថ្ងៃ Interface

១. អង្គជំនុំជម្រះសាលាដំបូង រំឭកឡើងវិញពីសេចក្តីសម្រេចពីមុនរបស់ខ្លួនថា ឯកសារទាំងអស់ដែលភាគីនានាមានបំណងប្រើប្រាស់ដើម្បីចោទសួរសាក្សី ឬ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែដាក់ចូលក្នុងប្រព័ន្ធដាក់ឯកសារសម្រាប់សវនាការប្រចាំថ្ងៃ Zylab (“Interface”) ឱ្យបានមុនថ្ងៃត្រង់ មួយថ្ងៃមុនពេលការផ្តល់សក្ខីកម្មចាប់ផ្តើម (“ពេលកំណត់”) (ឯកសារ E341 កថាខណ្ឌ ៣)។ អង្គជំនុំជម្រះ កត់សម្គាល់ថា ភាគីដែលយឺតយ៉ាវមិនអនុវត្តតាមថ្ងៃកំណត់នេះ បានចាប់ផ្តើមទម្លាប់ជាប្រចាំផ្ញើឯកសារបន្ថែម ឬ លេខឯកសារបន្ថែមតាមរយៈអ៊ីមែលទៅភាគីដទៃទៀត និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះ។ ដើម្បីចៀសវាងទម្លាប់នេះ អង្គជំនុំជម្រះបានអនុម័តយកបែបបទថ្មីដូចខាងក្រោមនេះដើម្បីជាប្រយោជន៍ធានាឱ្យមានកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និង ប្រសិទ្ធផល។

២. អង្គជំនុំជម្រះបានបង្គាប់ឱ្យអង្គភាពបណ្ណសារដកចេញការដាក់កំហិតនៅក្នុងប្រព័ន្ធ Interface ដែលមិនអនុញ្ញាតឱ្យដាក់ឯកសារបន្ទាប់ពីថ្ងៃកំណត់បានកន្លងផុត។ ប៉ុន្តែ ឥឡូវនេះមានបន្ថែមសញ្ញាប្រាប់វេលាដែលបង្ហាញថា នៅពេលណាដែលឯកសារត្រូវបានដាក់។ ឯកសារដែលបានដាក់ក្រោយថ្ងៃកំណត់ នឹងត្រូវគូសបង្ហាញនៅក្នុងប្រព័ន្ធ Interface។ ឯកសារបែបនេះអាចប្រើប្រាស់បានតែតាមឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះ ដោយពិចារណាថាតើ ការជូនដំណឹងយឺតពេលអំពីឯកសារទាំងនោះអាចប៉ះពាល់ដល់ភាគីដទៃទៀតដែរ ឬអត់ (ឯកសារ E341 កថាខណ្ឌ ៤)។ ហេតុដូច្នេះ ភាគីអាចជំទាស់នៅក្នុងសវនាការមិនឱ្យប្រើប្រាស់ឯកសារដែលបានដាក់ក្រោយថ្ងៃកំណត់។